# Statewide Specialist Clinical Consultation Service

*A service provided by the Queensland Transcultural Mental Health Centre*

## Consumer information sheet (Khmer)

## មណ្ឌលសុខភាពផ្លូវចិត្តឆ្លងកាត់វប្បធម៌រដ្ឋឃ្វីន្សឡែន

## កិច្ចបំរើពិគ្រោះយោបល់ព្យាបាលឆ្លងកាត់វប្បធម៌

## ប័ណ្ណព័ត៌មានសំរាប់អ្នកប្រើប្រាស់

លោកអ្នកទើបនឹងបានជួប**អ្នកពិគ្រោះយោបល់សុខភាពផ្លូវចិត្តម្នាក់ដែលចេះភាសាពីរ** (BMHC) របស់កិច្ចបំរើពិគ្រោះយោបល់ព្យាបាលឆ្លងកាត់វប្បធម៌។

ឈ្មោះនៃអ្នកពិគ្រោះយោបល់សុខភាពផ្លូវចិត្តចេះភាសាពីររបស់លោកអ្នកគឺ: ______________________________

កិច្ចបំរើពិគ្រោះយោបល់ព្យាបាលឆ្លងកាត់វប្បធម៌ (Transcultural Clinical Consultation Service) ផ្តល់កិច្ចបំរើដូចតទៅនេះ តាមរយៈអ្នកពិគ្រោះយោបល់សុខភាពផ្លូវចិត្តចេះភាសាពីរ:

- ពិនិត្យវាយតម្លៃដែលសមស្របតាមវប្បធម៌
- បកស្រាយបំភ្លឺបញ្ហាវប្បធម៌ ទាក់ទងនឹងបញ្ហាសុខភាពផ្លូវចិត្តរបស់លោកអ្នក
- ជំនួយក្នុងការបង្កើតឬពិនិត្យឡើងវិញនូវផែនការថែទាំរៀងខ្លួនរបស់លោកអ្នក
- ជំនួយរយៈពេលខ្លី ដូចជាព័ត៌មាននិងការអប់រំអំពីបញ្ហាសុខភាពផ្លូវចិត្តរបស់លោកអ្នក ជាមួយនឹងលោកអ្នកនិងអ្នកថែទាំលោកអ្នក

### សិទ្ធិរបស់លោកអ្នក

លោកអ្នកមានសិទ្ធិដើម្បី:

- ធ្វើសេចក្តីសំរេចចិត្តអំពីការថែទាំសុខភាពរបស់លោកអ្នកផ្ទាល់
- ទទួលជំនួយវិជ្ជាជីវ: ដោយពុំមានការប្រកាន់រើសអើង ដោយសារវប្បធម៌ អាយុ ឋានៈក្នុងសង្គម ភេទ ចំណូលចិត្តរួមភេទ ជំនឿសាសនាឬនយោបាយឡើយ
- ឲ្យគេពន្យល់តាមពាក្យសម្តីដែលលោកអ្នកអាចយល់បាន នូវស្ថានភាពឬជំងឺ និងផែនការគ្រប់គ្រងរបស់លោកអ្នក
- មានអ្នកជំនួយម្នាក់ (មិត្តភក្តិ សាច់ញាតិ បុគ្គលិកជំនួយ) ឲ្យចូលរួមក្នុងគ្រប់ផ្នែកទាំងអស់នៃការថែទាំលោកអ្នក
- ឲ្យមានការគោរពភាពផ្ទាល់ខ្លួននិងការលាក់ការសម្ងាត់របស់លោកអ្នក
- សុំឲ្យមានឬទទួលអ្នកបកប្រែភាសា បើត្រូវការ
- ធ្វើបណ្តឹងអំពីផ្នែកណាមួយនៃការថែទាំលោកអ្នក បើលោកអ្នកមិនពេញចិត្តទេនោះ

### ការទទួលខុសត្រូវរបស់លោកអ្នក

លោកអ្នកគួរធ្វើការជាមួយអ្នកវិជ្ជាជីវ:សុខភាពផ្លូវចិត្តម្នាក់ និងជួយដល់ការថែទាំសុខភាពរបស់លោកអ្នកផ្ទាល់ ដោយ:

- ឆ្លើយនឹងសំណួរអំពីសុខភាពលោកអ្នក ដោយបើកចំហឲ្យអស់លទ្ធភាព
- ធ្វើតាមការណាត់ជួបរបស់លោកអ្នក ហើយប្រាប់បុគ្គលិកសុខភាពលោកអ្នកឲ្យដឹង បើលោកអ្នកមិនអាចទៅជួបតាមការណាត់ជួបទេនោះ
- ធ្វើតាមការព្យាបាលឬការគ្រប់គ្រងដែលលោកអ្នកបានយល់ព្រម ហើយប្រាប់បុគ្គលិកសុខភាពលោកអ្នក បើលោកអ្នកសំរេចថាមិនធ្វើការព្យាបាលតទៅទៀតទេ
- ប្រាប់បុគ្គលិកសុខភាពលោកអ្នកឲ្យដឹង បើលោកអ្នកកំពុងជួបបុគ្គលិកថែទាំសុខភាពម្នាក់ទៀតអំពីបញ្ហាដដែលនេះ

បើលោកអ្នកត្រូវការព័ត៌មានបន្ថែម ឬមានបំណងពិភាក្សាការបារម្ភរបស់លោកអ្នក ឬចង់ធ្វើបណ្តឹង សូមទាក់ទងអ្នកសំរបសំរួលកិច្ចបំរើព្យាបាល (Clinical Services Co-ordinator) ឬ ប្រធាននៅឯមណ្ឌលសុខភាពផ្លូវចិត្តឆ្លងកាត់វប្បធម៌រដ្ឋឃ្វីន្សឡែន តាមទូរស័ព្ទលេខ

(07) 3167-8333 ឬ 1800 188 189 (ទូរស័ព្ទឥតគិតថ្លៃ នៅក្រៅតំបន់ទីក្រុង Brisbane) ឬមួយលោកអ្នកអាចផ្ញើអ៊ីមែលទៅ TCCS@health.qld.gov.au

បើលោកអ្នកមិនចេះនិយាយភាសាអង់គ្លេសទេ សូមទូរស័ព្ទទៅលេខ 131450 ដើម្បីសុំឲ្យមានអ្នកបកប្រែភាសាលោកអ្នក ហើយសុំឲ្យតភ្ជាប់ទៅទូរស័ព្ទលេខ (07) 3167-8333 (មណ្ឌលនេះនឹងចេញថ្លៃសំរាប់អ្នកបកប្រែភាសា)។